# មិត្តនគរបាល
POLICEFRIENDSHIPMAGAZINE

ទស្សនាវដ្ដី

លេខ ១០៨/ វិច្ឆិកា-ធ្នូ / ២០២២

## អរគុណសន្តិភាព











យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង គ្រួសារយើង និងសង្គមជាតិយើង

# គណៈកម្មការនិពន្ធ

## នាយកគ្រប់គ្រង

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ប៊ុនណារិន**

## និពន្ធនាយក

ឧត្តមសេនីយ៍ឯក សៀង សុវត្ថិ

## និពន្ធនាយករង

ឧត្តមសេនីយ៍ទោ ប៉ុក សុជាតិ

វរសេនីយ៍ឯក ប៉ុក រដ្ឋា



## យកព័ត៌មាន និពន្ធ

-វរសេនីយ៍ទោ ចាប ភ័ស្ត (ប្រធានក្រុម)

-វរសេនីយ៍ត្រី ប៉ុក គន្ធារ៉ូ

-អនុសេនីយ៍ឯក គន សេរី

## ថតរូប

-វរសេនីយ៍ទោ ជិន ម៉ូលីដា (ប្រធានក្រុម)

-អនុសេនីយ៍ឯក ស្រ៊ី ឈុនឡេង

-អនុសេនីយ៍ឯក លន់ ឈាងសេង

-អនុសេនីយ៍ឯក ព្រុំ ចាន់តារា

## ចែកផ្សាយ

-វរសេនីយ៍ទោ ង៉ាន សុផាប (ប្រធានក្រុម)

-វរសេនីយ៍ត្រី សុន សៀង

## រចនាទំព័រ

-អនុសេនីយ៍ឯក ម៉ុង រិទ្ធី (ប្រធានក្រុម)

-អនុសេនីយ៍ឯក អុន ពិសិទ្ធ

## ពិនិត្យអក្ខរាវិរុទ្ធ

-វរសេនីយ៍ទោ ញឹម ហឿន (ប្រធានក្រុម)

-អនុសេនីយ៍ឯក វ៉ាន់ វិបុល

## កីឡា និងសិល្បៈ

-វរសេនីយ៍ត្រី ជឹម ធី (ប្រធានក្រុម)

-អនុសេនីយ៍ឯក មុត សីហា



# សូមគោរពជូនពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ

**ជូនចំពោះ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**



## ក្នុងឱកាសខួបកំណើត គម្រប់ ៧២ឆ្នាំ ឈានចូល ៧៣ឆ្នាំ

សូមសម្តេចទទួលបាននូវសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ កម្លាំងពលំខ្លាំងក្លា
ប្រាជ្ញាឈ្លាសវៃ ដើម្បីរួមចំណែកដឹកនាំកសាង និងអភិវឌ្ឍមាតុភូមិកម្ពុជា
ឱ្យកាន់តែរីកចម្រើនរុងរឿងឆ្ពោះទៅរកសុខសន្តិភាព សុភមង្គលដ៏យូរអង្វែងតរៀងទៅ ។



**សូមគោរពជូនពរពី**

គណៈកម្មការនិពន្ធទស្សនាវដ្តី មិត្តនគរបាល POLICE FRIENDSHIP MAGAZINE

**នាយកគ្រប់គ្រង**

ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ច៊ុនណារិន

# ប្រកាសដាក់ឲ្យប្រើជាផ្លូវការ ចក្ខុវិស័យ និងយុទ្ធសាស្រ្ត ស្តីពី « សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល »








កាលពីរសៀលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសដាក់ឲ្យប្រើជាផ្លូវការ ចក្ខុវិស័យ និងយុទ្ធសាស្ត្រ ស្តីពី « **សុខដុមនីយកម្មការកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល** » ប្រារព្ធនៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ។

ឯកឧត្តម **ហ៊ែល ចំរើន** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) បានធ្វើសេចក្តីរាយការណ៍សង្ខេប ស្តីពី ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រស្តីពី " **សុខដុមនីយកម្មការកែទម្រង់៣បូក១នៃរាជរដ្ឋា**



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# មិត្តនគរបាល
POLICEFRIENDSHIPMAGAZINE

ទស្សនាវដ្ដី

លេខ ១០៨/ វិច្ឆិកា-ធ្នូ / ២០២២

អរគុណសន្តិភាព










យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង

# សម្តេចក្រឡាហោម ទទួលមេដាយមាស ក្នុងសន្និសីទលើកទី ១ នៃវេទិកា



នារសៀលថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញចូលរួមទទួល មេដាយមាស Great Wall Commemorative Medal តាមប្រព័ន្ធវីដេអូ ក្នុងសន្និសីទលើកទី១ នៃវេទិកាកិច្ចសហប្រតិបត្តិការសន្តិសុខសាធារណៈសកល នៅទីស្តីការក្រសួងមហាផ្ទៃ ។





ក្នុងនាមរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃនៃ ព្រះរាជាណាចក្រកម្ពុជា **សម្តេចក្រឡាហោម** បានថ្លែងនូវសេចក្តីសោមនស្សរីករាយដែលត្រូវបានរដ្ឋាភិបាល និងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិន ផ្តល់នូវគ្រឿងឥស្សរិយយស « **មេដាយមាស មេដាយ** ប្រាក់ **អនុស្សាវរីយ៍មហាកំផែង** » ក្នុងឱកាសនៃការប្រារព្ធពិធីដ៏មហោឡារិក



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 9:59 AM

# Great Wall Commemorative Medal
# កិច្ចសហប្រតិបត្តិការសន្តិសុខសាធារណៈសកល







វេទិកាកិច្ចសហប្រតិបត្តិការសន្តិសុខសាធារណៈសកល លើកទី ៦ ឬហៅថា វេទិកា« **លានស៊ុនកាង** » (Lianyungang ) នាពេលនេះ ។

**សម្តេចក្រឡាហោម** បានប្រសាសន៍បន្តថា៖ ការទទួលបាននូវគ្រឿងឥស្សរិយយសប្រកបដោយគុណតម្លៃពិសេសវិសាលនេះ គឺជាមោទកភាពសម្រាប់រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃកម្ពុជា ដែលជាស្ថាប័នទទួលខុសត្រូវក្នុងភារកិច្ចថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។ ក្នុងន័យនេះ «**មេដាយមាស មេដាយប្រាក់ អនុស្សាវរីយ៍មហាកំពែង** » មិនត្រឹមតែជាការលើកទឹកចិត្តសម្រាប់ **សម្តេច** ផ្ទាល់ ព្រមទាំងឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងឯកឧត្តម ឧត្តមសេនីយ៍ឯក **ឌី វិជ្ជា** អគ្គស្នងការរងនគរបាលជាតិប៉ុណ្ណោះទេ ប៉ុន្តែ គឺជាការលើកទឹកចិត្តដ៏ខ្លាំងក្លាមួយបន្ថែមទៀត ដល់សមត្ថកិច្ចអនុវត្តច្បាប់របស់កម្ពុជា ទាំងមូលក្នុងកិច្ចសហប្រតិបត្តិការរបស់ខ្លួន ដើម្បីបម្រើដល់បុព្វ

៥២



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/pebw/

# សម្តេចក្រឡាហោម ទទួលជួបពិភាក្សាការងារ ជាមួយឯកអគ្គរដ្ឋទូត សហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា



នារសៀលថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យ ឯកឧត្តម W. Patrick Murphy (**ដាប់ប៊ែលយូ ប៉ាទ្រីក មូហ្វី**) ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ចូលជួបពិភាក្សាការងារ នៅវិមានរដ្ឋសភា ។

នៅក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** បានសម្តែងនូវការស្វាគមន៍ឯកឧត្តមឯកអគ្គរដ្ឋទូត និងថ្លែងអំណរគុណចំពោះកិច្ចសហការដែលសហរដ្ឋអាមេរិកមានជាមួយកម្ពុជា លើវិស័យជាច្រើន ជាពិសេសនៅក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលជាការរួមចំណែកមួយធ្វើឱ្យកម្ពុជា ទទួលបានជោគជ័យលើការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត រហូតឈានទៅដល់ការបើកដំណើរការប្រទេសជាតិឡើងវិញ ។

ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានសម្តែងនូវសេចក្តីរីករាយចំពោះកិច្ចសហប្រតិបត្តិការរវាងកម្លាំងអនុវត្តច្បាប់នៃប្រទេសទាំងពីរ និងបានជម្រាបជូនឯកឧត្តម ឯកអគ្គរដ្ឋទូតដែរថា នាពេលឆាប់ៗដ៏ខ្លីខាងមុខនេះ ថ្នាក់ដឹកនាំក៏ដូចជាមន្ត្រីរាជការ និងប្រជាជនកម្ពុជានឹងទទួលស្វាគមន៍បណ្តាថ្នាក់ដឹកនាំក្នុងតំបន់ និងអន្តរជាតិអញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ក្នុងនោះកម្ពុជាក៏មានសេចក្តីរីករាយ និងស្វាគមន៍វត្តមានឯកឧត្តមប្រធានាធិបតីសហរដ្ឋអាមេរិកមកកាន់កម្ពុជាផងដែរ ។

**សម្តេចក្រឡាហោម** បានចាត់ទុកវត្តមាន ឯកឧត្តមប្រធានាធិបតីសហរដ្ឋអាមេរិកនាពេលនេះ ថាមិនត្រឹមតែជាការផ្តល់តម្លៃលើទំនាក់ទំនងរវាងកម្ពុជា និងអាស៊ាន ក៏ដូចជារវាងសហរដ្ឋអាមេរិក និងអាស៊ានប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ជាការផ្តល់តម្លៃ និងជាការលើកកម្ពស់នូវទំនាក់ទំនង



៣គាំពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







និងកិច្ចសហប្រតិបត្តិការរវាងសហរដ្ឋអាមេរិក និងកម្ពុជាផងដែរ ដែលតាមរយៈនេះបានបញ្ជាក់ឱ្យឃើញថាកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងប្រទេសទាំងពីរនឹងបន្តរីកចម្រើនឥតឈប់ឈរ ។

**សម្តេចក្រឡាហោម** ក៏បានបង្ហាញនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង ក៏ដូចជាតួនាទីដ៏មានសារៈសំខាន់របស់ ឯកឧត្តម ឯកអគ្គរដ្ឋទូត ដែលតែងតែខិតខំជំរុញដល់ការលើកកម្ពស់នូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរផងដែរ ។

ជាការឆ្លើយតប ឯកឧត្តម ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានយកឱកាសនេះថ្លែងអំណរគុណដល់អាជ្ញាធរកម្ពុជាគ្រប់ស្ថាប័នពាក់ព័ន្ធដែលបានជួយសម្របសម្រួលដល់សំណើផ្សេងៗក្នុងការសម្រួលដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំសហរដ្ឋអាមេរិកមកកាន់កម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកនេះ ។

ដោយឡែកពាក់ព័ន្ធទៅលើយុទ្ធនាការក៏ដូចជាលទ្ធផលនៃការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដែលកម្ពុជាបានអនុវត្តក្នុងរយៈពេលកន្លងមកនេះ ឯកឧត្តមកត់សម្គាល់ឃើញថាមួយរយៈនេះមានបទល្មើសមួយចំនួនបានកើតឡើងជាពិសេសពាក់ព័ន្ធទៅនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដែលបានធ្វើឱ្យប្រជាពលរដ្ឋនៃប្រទេសមួយចំនួនត្រូវចាញ់បោកឧក្រិដ្ឋជននាំឆ្លងដែនចូលមកកម្ពុជាដោយខុសច្បាប់ដែលបញ្ហានេះ ឯកឧត្តមបានសម្តែងនូវការអបអរសាទរ និងកោតសរសើរចំពោះជំហានរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា **សម្តេចក្រឡាហោម** នៅក្នុងការដោះស្រាយនូវបញ្ហាដ៏មានសារៈសំខាន់នេះ ។

ជាការឆ្លើយតប **សម្តេចក្រឡាហោម** បានជម្រាបជូនថា៖ នៅក្នុងក្របខណ្ឌនៃឆន្ទៈនយោបាយ គឺរាជរដ្ឋាភិបាលកម្ពុជាពុំមានអ្វីប្រែប្រួលនោះទេចំពោះការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេះ គឺដូចអ្វីដែល ឯកឧត្តម ឯកអគ្គរដ្ឋទូតបានលើកឡើង ព្រោះថាបច្ចុប្បន្ននេះទម្រង់នៃអំពើជួញដូរមនុស្សមានការវិវឌ្ឍន៍ប្រែប្រួលដោយសារតែមានការផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ក៏ដូចជាបច្ចេកវិទ្យាព័ត៌មានក្នុងការប្រព្រឹត្តបទល្មើស ។

៤១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សម្តេចក្រឡាហោម អញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខា បន្តសុពលភាព MOU រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រុមហ៊ុន ESS









នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **មីកាមិ ម៉ាសាហ៊ីរុ** ( MIKAMI Masahiro ) ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាបាន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីចុះហត្ថលេខាបន្តសុពលភាពលើឧបសម្ព័ន្ធអនុស្សរណៈនៃការយោគយល់គ្នា ( MOU ) រវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងក្រុមហ៊ុន E SECURITY SERVICE Co,Ltd ( ESS ) ។

ឧបសម្ព័ន្ធអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងក្រុមហ៊ុន ESS នាពេលនេះ គឺបញ្ជាក់អំពីការបន្តសុពលភាពរយៈពេល ១០ឆ្នាំ បន្ថែមលើអនុស្សរណៈនៃការយោគយល់គ្នាច្បាប់ដើម ស្តីពីការសហការផ្តល់សេវាកម្មព័ត៌មាន សន្តិសុខរវាងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃកម្ពុជា និងក្រុមហ៊ុន ESS ដែលផុតសុពលភាព កាលពីថ្ងៃទី១៦



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 9:59 AM




ខែវិច្ឆិកា ឆ្នាំ២០២២ ដោយគ្មានការផ្លាស់ប្តូរខ្លឹមសារ ដូចមានចែងក្នុងមាត្រានៃអនុស្សរណៈនៃការយោគយល់គ្នាច្បាប់ដើម នោះទេ ។

លោក **តាកេខេហារូ មីហ្សូកូស៊ី** (TAKEHARU MIZUKOSHI) នាយកប្រតិបត្តិក្រុមហ៊ុន ESS បានធ្វើសេចក្តីរាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនESSថា ៖ ក្នុងឆ្នាំ២០១២ បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃកម្ពុជា ក្នុងការបង្កើតអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រុមហ៊ុន ESS រួចមក ទាំងភាគីក្រុមហ៊ុន និងកងកម្លាំងនគរបាលជាតិកម្ពុជា បានសហការគ្នាចាត់តាំងអនុវត្តស្របតាមស្មារតី និងខ្លឹមសារដូចមានចែងក្នុង MOU ដោយផ្តោតសំខាន់ទៅលើការចូលរួមការពាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋកម្ពុជា និងធុរជនដែលជាអតិថិជនរបស់ក្រុមហ៊ុ ន្ផ្ទាល់ ។

លោក នាយកប្រតិបត្តិក្រុមហ៊ុ ន ESS បានបញ្ជាក់បន្តថា៖ ដោយឡែកតាមរយៈឧបករណ៍ សម្ភារបច្ចេកទេស និងប្រព័ន្ធផ្តល់សញ្ញាសន្តិសុខរបស់ក្រុមហ៊ុន




និងដោយមានការគាំទ្រសម្របសម្រួលពីមជ្ឈមណ្ឌលប្រចាំបញ្ជាការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងមជ្ឈមណ្ឌលប្រចាំបញ្ជាការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត កិច្ចសហការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងបង្ការទប់ស្កាត់ បទល្មើសទទួលបានលទ្ធផលជាច្រើនផងដែរ ។

លោក នាយកប្រតិបត្តិក្រុមហ៊ុន ESS ក៏បានបញ្ជាក់ជម្រាបជូន **សម្តេចក្រឡាហោម** និងអង្គពិធីថា ក្រុមហ៊ុន ESS ដែលកំពុងមានវត្តមាននៅកម្ពុជា និងបានអនុវត្តនីតិវិធីសុពលភាព MOU កន្លងមកបានសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរកម្ពុជា និងបានផ្តល់សេវាកម្មជូនដល់អតិថិជនកម្ពុជាបានជាច្រើន ដែលក្នុងនោះរួមមានដូចជា ករណីចោរកម្ម អគ្គិភ័យ គ្រោះទឹកជំនន់ សង្គ្រោះបន្ទាន់ជាដើម ។

គួររំលឹកផងដែរថា៖ ពិធីចុះ MOU បន្តសុពលភាពនៃការយោគយល់គ្នារវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងក្រុមហ៊ុន ESS នាពេលនេះ គឺធ្វើឡើងបន្ទាប់ពីមានការស្នើសុំពី លោក **អូគូបូ ហ៊ីដូ** (OKUBO Hideo) ជាស្ថាបនិកមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា ហៅកាត់CIESF នាឱកាសសុំការអនុញ្ញាតចូលជួបសម្តែងការគួរសមជាមួយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីទី២១ ខែកញ្ញា ឆ្នាំ២០២២ ដែលអនុស្សរណៈនេះត្រូវបានផុតសុពលភាពនៅអំឡុង ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមក ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/pebw/



# ទិវាជាតិ ១២ ធ្នូ ប្រឆាំងការជួញដូរ

## « រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅ

នារសៀលថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្ដីទីនៃរាជរដ្ឋាភិបាលកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីអបអរទិវាជាតិ១២ធ្នូប្រឆាំងការជួញដូរមនុស្សឆ្នាំ២០២២ ក្រោមប្រធានបទ « ***រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព*** » ប្រារព្ធនៅមជ្ឈមណ្ឌលកោះពេជ្រ ។









៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# មនុស្ស ឆ្នាំ ២០២២ ក្រោមប្រធានបទ
## សម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព »

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបញ្ជាក់ថា៖ ក្នុងឆមាសទី១ នៃឆ្នាំ ២០២២ ស្ថានភាពនៃអំពើជួញដូរមនុស្ស មានភាពល្អប្រសើរ ដោយអត្រានៃបទល្មើស បានថយចុះ គួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងឆ្នាំ២០២១ ។ គិតចាប់ពីថ្ងៃទី១៨ ខែសី ហាមកដល់ខែវិច្ឆិកា

☞ ១១



លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ
និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ១០

**ទិវាជាតិ ១២ធ្នូ ប្រឆាំងការជួញដូរមនុស្ស...**

ឆ្នាំ២០២២ កន្លងទៅ គឺក្នុងចំណោមអ្នកដែលបានប្រកាសថា ជាជនរងគ្រោះសុំឱ្យផ្ញើអន្តរាគមន៍ជួយសង្គ្រោះ គ.ជ.ប.ជ បានរកឃើញមនុស្សចំនួន ១.១២២នាក់ ស្រី ១២១នាក់ ហើយ តែក្នុងចំណោមជនទាំងនោះអ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំងខ្លួន និងពលកម្មដោយបង្ខំ ១៥៣នាក់ ស្រី ១៨នាក់ មាន៦សញ្ជាតិ ចំណែកជនក្រៅពីនេះបានបដិសេធថាខ្លួនមិនបានទទួលភាពរងគ្រោះទេ និងមានបំណងចង់ប្ដូរទៅទីតាំងការងារថ្មីដែលមានប្រាក់ខែខ្ពស់ជាងនេះ ឬថាគ្រាន់តែជាការបារម្ភរបស់ក្រុមគ្រួសារតែប៉ុណ្ណោះ ។

លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ **គ.ជ.ប.ជ** បានបញ្ជាក់បន្តថា៖ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែនាំចេញពីទីតាំងដែលពាក់ព័ន្ធនឹងបទល្មើស ដើម្បីសុវត្ថិភាពពលករ និងមិនអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ទីតាំងទាំងនោះវិញឡើយ ហើយគិតពីចាប់ផ្ដើមប្រតិបត្តិការដល់ត្រឹមថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ជនសង្ស័យ២២នាក់ មានបីសញ្ជាតិ ដែលសង្ស័យពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស ២២នាក់ និងជនសង្ស័យពាក់ព័ន្ធនឹងអំពើជួញដូរផ្លូវភេទ ០៤នាក់ ០១ សញ្ជាតិ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់កម្ពុជា ។ រីឯទីតាំងសង្ស័យប្រព្រឹត្តបទល្មើស ចំនួន៥ ត្រូវបានបិទជាស្ថាពរ និងបួនទីតាំងបិទបណ្ដោះអាសន្ន ដើម្បីស្រាវជ្រាវរកបទល្មើស ។



៣កាពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



**សម្តេចក្រឡាហោម** នាយករដ្ឋមន្ត្រីស្តីទី និងជាប្រធាន គ.ជ.ប.ជ មានប្រសាសន៍ថា៖ ឆ្នាំ ២០២២នេះ ជាឆ្នាំដែលមានឱកាសអាចរៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្សក្រោមប្រធានបទ «**រួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស ឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព** » ដែលស្របទៅទស្សនវិស័យ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរក្សានូវសន្តិសុខ សុវត្ថិភាពសង្គម ដើម្បីជាមូលដ្ឋានបង្អែកនៃការអភិវឌ្ឍន៍ជាតិគ្រប់វិស័យក្នុងរយៈពេលវែង ។ គ.ជ.ប.ជ តែងប្រារព្ធរៀបចំកម្មវិធីទិវាជាតិនេះជារៀងរាល់ឆ្នាំយ៉ាងអធិកអធម ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងតាមបណ្តាសាលារៀនគ្រប់ច្រកល្ហកនៅទូទាំងប្រទេស ដែលមានអ្នកចូលរួមរហូតដល់រាប់សែននាក់។

**សម្តេចក្រឡាហោម** មានប្រសាសន៍បញ្ជាក់ទៀតថា៖ ចរន្តនៃការវិលត្រឡប់មកវិញដោយឥតគ្រោងទុករបស់ពលករកម្ពុជាពីប្រទេសគោលដៅក្នុងអំឡុងកូវីដ-១៩ ជាពិសេសក្នុងឆ្នាំ២០២០ និង ២០២១ បានកើនរហូតដល់ជាង ៣០ម៉ឺននាក់ និងថាក្នុងដំណាក់កាលនេះហើយដែលការគ្រប់គ្រងព្រំដែនមានភាពប្រឈមស្មុគស្មាញ ដោយចំនួននៃពលករវិលត្រឡប់កើនឡើងយ៉ាងគំហុក ជារៀងរាល់ថ្ងៃ ក្នុងនោះជនទេសន្តរប្រវេសន៍បរទេសខុសច្បាប់ជាច្រើន មានឱកាសបន្លំខ្លួនចូលមកកម្ពុជា ដោយខុសច្បាប់ និងបានសម្ងំលាក់ខ្លួនធ្វើការងារជាមួយនិយោជកទុច្ចរិតមួយចំនួន ដែលបង្កើតបានជាបទល្មើសយ៉ាងអាណាធិបតេយ្យ លើទឹកដីកម្ពុជា ។

ស្ថិតក្នុងស្ថានភាពបែបនេះ រាជរដ្ឋាភិបាលកម្ពុជា មិនបានព្រងើយកន្តើយឡើយ បានដាក់ចេញនូវវិធានការប្រតិបត្តិការ ដើម្បីរុករក បង្ក្រាប និងបោសសម្អាតបទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសពាក់ព័ន្ធផ្សេងទៀត យ៉ាងសកម្មតាមវិធានការច្បាប់ រហូតធ្វើឲ្យកម្ពុជាវិលត្រឡប់មករកស្ថានភាពសុវត្ថិភាព និងសន្តិសុខជាប្រក្រតីឡើងវិញ នៅទូទាំងផ្ទៃប្រទេស និងថារាជរដ្ឋាភិបាលកម្ពុជានៅតែបន្តការប្តេជ្ញាចិត្តខ្ពស់ក្នុងការបង្ការទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសអំពើជួញដូរមនុស្ស និងបន្តអនុវត្តរាល់បទដ្ឋានដែលជាប្រយោជន៍ដល់ការលើកកម្ពស់ការគោរពសិទ្ធិ និងកិច្ចការពារសុវត្ថិភាពមនុស្សជាតិ ។

**សម្តេចក្រឡាហោម** មានប្រសាសន៍បន្ថែមថា« កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការរៀបចំអនុម័តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ ដែលហៅកាត់ថា GCM រហូតត្រូវបានការទទួលស្គាល់ពីអង្គការសហប្រជាជាតិផ្នែកទេសន្តរប្រវេសន៍ ថាជា « **ប្រទេសជើងឯកនៃគំនិតផ្តួចផ្តើមរបស់កតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ ក្នុងការប្តេជ្ញាចិត្តខ្ពស់ការពារផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ពលករទេសន្តរប្រវេសន៍ និងការពារពួកគេពីភាពរងគ្រោះ ដោយការរំលោភបំពាន និងកេងប្រវ័ញ្ច គ្រប់រូបភាព** » ។

**សម្តេចក្រឡាហោម** បានអំពាវនាវថ្នាក់ដឹកនាំ មន្ត្រីរាជការ អាជ្ញាធរ កម្លាំងសមត្ថកិច្ច និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំតាមដានបាតុភាព និងបទល្មើសផ្សេងៗ និងគ្រប់គ្រងព្រំដែនឲ្យបានគត់មត់ ដើម្បីទប់ស្កាត់មូលហេតុរួមផ្សំដែលនាំឲ្យមានអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្សេងៗ រួមគ្នាលុបបំបាត់ការធ្វើទេសន្តរប្រវេសន៍ដែលគ្មានសុវត្ថិភាព ខុសច្បាប់ និងការងារខុសច្បាប់ ។ សម្តេចក៏បានអំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់និកាយសាសនា បន្តការផ្សព្វផ្សាយខ្លឹមសារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដល់សាសនិកទាំងឡាយនៅតាមសហគមន៍ទូទាំងប្រទេស ឲ្យបានយល់ជ្រួតជ្រាប ខ្លឹមសារពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមវិធានការ និងបានលើកទឹកចិត្តដល់គ្រប់វិស័យពាក់ព័ន្ធជាតិ និងអន្តរជាតិ សូមបន្តរិះរកនូវវិធានការជាគន្លឹះនានា និងរួមសហការគ្នាជាធ្លុងមួយ ធ្វើសកម្មភាពឲ្យកាន់តែខ្លាំងក្លាក្នុងការបង្ការ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដើម្បីព្រះរាជាណាចក្រកម្ពុជា គ្មានអំពើជួញដូរមនុស្ស ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ពង្រាងផែនការជាតិទសវត្សរ៍សុវត្ថិភាព

## មានគោលបំណងកាត់បន្ថយអ្នកស្លាប់ និង អ្នករបួស

នៅព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ( គ.ស.ច.គ ) បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ដឹកនាំកិច្ចប្រជុំឆ្លងពង្រាងផែនការជាតិទសវត្សរ៍សុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ស.ច.គ ឯកឧត្តម និងលោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករងនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងអស់លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គលេខាធិការដ្ឋាន គ.ស.ច.គ ជាច្រើនរូបទៀត ។







៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ចរាចរណ៍ផ្លូវគោកលើកទី ២(២០២១-២០៣០)
## ដោយគ្រោះថ្នាក់ចរាចរណ៍ឲ្យបាន ៥០ភាគរយនៅឆ្នាំ ២០៣០





អញ្ជើញមានប្រសាសន៍បើកកិច្ចប្រជុំនាពេលនោះ **សម្តេចក្រឡាហោម** បានថ្លែងអំណរគុណ និងកោតសរសើរអគ្គលេខាធិការដ្ឋាន គ.ស.ច.គ. ដែលបានខិតខំសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំសេចក្តីព្រាងផែនការជាតិនេះឡើង និងបានសម្តែងការពេញចិត្តចំពោះផែនការនេះ ដ្បិតមានទស្សនវិស័យវែងឆ្ងាយ និងប្រាកដនិយមក្នុងការដោះស្រាយបញ្ហាចរាចរណ៍នៅកម្ពុជា ។ **សម្តេច** បានឯកភាពចំពោះយោបល់ស្នើឱ្យ គ.ស.ច.គ ពិនិត្យលទ្ធភាពពិចារណាស្នើសុំរាជរដ្ឋាភិបាលកំណត់ឆ្នាំផលិតរថយន្តនាំចូលមកកម្ពុជា ដើម្បីកាត់បន្ថយរថយន្តដុះមានហានិភ័យ និងបានជំរុញឱ្យខិតខំបន្ថែមទៀតក្នុងការបំពាក់ការម៉ាសុវត្ថិភាពនៅតាមដងផ្លូវ ។

☞ ៥១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សិក្ខាកាមវគ្គសុក្រឹតការ
## ថ្នាក់ដឹកនាំនគរបាលជាតិកម្រិត ១ និងកម្រិត ២ ជំនាន់ទី II
## ចំនួន ១៩៤នាក់ បានបញ្ចប់វគ្គសិក្សា ប្រកបដោយជោគជ័យ





នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ នៅបណ្ឌិត្យសភានគរបាលកម្ពុជា សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាល កម្រិត១ និងកម្រិត២ ជំនាន់ទី២ស្ថិតនៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិតសភានគរបាលកម្ពុជា បានរាយការណ៍ជូន **សម្តេចក្រឡាហោម** និងអង្គពិធីជ្រាបថា៖ វគ្គសុក្រឹតការទាំង២កម្រិតនេះ មានគោលបំណងពង្រឹងសមត្ថភាពវិជ្ជាជីវៈថ្នាក់ដឹកនាំនគរបាលជាតិក្នុងមុខតំណែង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារដឹកនាំគ្រប់គ្រងនៅតាមអង្គភាពព្រមទាំងជាវគ្គដែលមានតម្លៃ និងមាន



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





សារសំខាន់ និងជំនាញវិជ្ជាជីវៈនគរបាល ក្នុងការបំពេញតួនាទីជាថ្នាក់ដឹកនាំគ្រប់កម្រិតទាំងបច្ចុប្បន្ន និងអនាគត ។

ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ បានបន្តថា៖ ថ្វីត្បិតតែវគ្គសិក្សានេះមានរយៈពេលខ្លី តែខ្លឹមសារនៃមុខវិជ្ជា និងមេរៀននីមួយៗត្រូវបានសម្រិតសម្រាំងឱ្យបានល្អ ដើម្បីបំពេញនូវចំណុចខ្វះខាតបន្ថែមលើចំណេះដឹង ជំនាញនិងបទពិសោធន៍របស់សិក្ខាកាមដែលមានស្រាប់ ។ ជាមួយគ្នា នេះដែរបណ្ឌិត្យសភានគរបាលបានជ្រើសរើសសាស្ត្រាចារ្យគ្រូនគរបាលជាតិ និងវាគ្មិនដែលមានគុណវុឌ្ឍិ សមត្ថភាព បទពិសោធន៍ខ្ពស់ ដើម្បីមកបង្ហាត់បង្រៀន និងធ្វើបទបាឋកថាលើប្រធានបទនានា ដើម្បីផ្តល់ចំណេះដឹង និងចែករំលែកបទពិសោធន៍ដល់សិក្ខាកាមបន្ថែមទៀត ។



ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ **សេង ផល្លី** ប្រធានបណ្ឌិតសភានគរបាលកម្ពុជា



ឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រា ចារ្យ បានបន្តទៀតថា៖ ក្នុងរយៈពេលសិក្សាសិក្ខាកាម គោរពវិន័យបានល្អ ស្របតាមបទបញ្ជាផ្ទៃក្នុងដែលបានកំណត់ ខិតខំយកចិត្តទុកដាក់សិក្សារៀនសូត្រ មានសាមគ្គីភាពផ្ទៃក្នុងល្អ មានទំនាក់ទំនងល្អ និងរាប់អានគ្នាស្និទ្ធស្នាលប្រកបដោយភាតរភាព ។



នៅពេលបញ្ចប់វគ្គសិក្សា មានសិក្ខាកាមជ័យលាភីចំនួន **១៩៤១៩៨** នាក់ ដែលទទួលបាននិទ្ទេស ដូចខាងក្រោម៖

៤២



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ពិធីប្រគល់-ទទួល អគារទីបញ្ជាការ
## អង្គភាពនគរបាលការពារបេតិកភណ្ឌ ប្រចាំប្រាសាទបន្ទាយឆ្មារ
### ខេត្តបន្ទាយមានជ័យ

កាលពីរសៀលថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលអគារទីបញ្ជាការអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំប្រាសាទបន្ទាយឆ្មារ ខេត្តបន្ទាយមានជ័យ ដោយមានការអញ្ជើញចូលរួមអមដំណើរពីសំណាក់ ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ប៊ុនណារិន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ឯកឧត្តម នាយឧត្តមសេនីយ៍ **សេខ យូអ៊ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ព្រមទាំងតំណាងស្ថាប័នពាក់ព័ន្ធនានាជាច្រើនរូបទៀត ។







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



ជាមួយ និងការពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ **សម្តេចក្រឡាហោម** ជូនចំពោះអង្គពិធីទាំងមូល ឯកឧត្តម រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ បានមានប្រសាសន៍ កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះបណ្តាអង្គភាពពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការកសាងទីបញ្ជាការ



អង្គភាពនគរបាលការពារបេតិកភណ្ឌ ឱ្យបានរួចរាល់តាមការគ្រោងទុក ដើម្បីក្លាយជាទីបញ្ជាការការពារដ៏រឹងមាំសំដៅការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនដល់គណៈប្រតិភូជាតិ-អន្តរជាតិ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ ក៏ដូចជាការការពារនូវសម្បត្តិវប្បធម៌ជាតិ ការទប់ស្កាត់នូវរាល់សកម្មភាពបំផ្លិចបំផ្លាញ ដូចជាករណីលួចវត្ថុបុរាណ ឬជីករុករក និងដឹកជញ្ជូនវត្ថុបុរាណខុសច្បាប់ ។ល។ សក្ខីភាពទាំងអស់នេះបានបញ្ជាក់យ៉ាងច្បាស់ថា៖ អគ្គស្នងការដ្ឋាន

៤៤





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# កិច្ចប្រជុំលើកទី ២០ របស់ គ ជ អ ប
## បញ្ហាប្រឈម និង





នាព្រឹកថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្តីទី បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំលើកទី២០ របស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដោយមានការអញ្ជើញចូលរួមផ្ទាល់ និងតាមរយៈប្រព័ន្ធវីដេអូសន្និសីទ ពីសំណាក់ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនរូបទៀត ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់ថា៖ កិច្ចប្រជុំនាពេលនេះ គឺពិនិត្យ ពិភាក្សាលើវឌ្ឍនភាព បញ្ហាប្រឈម និងពិភាក្សាលើសេចក្តី ព្រាង



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ពិនិត្យពិភាក្សាលើវឌ្ឍនភាព
# សេចក្តីព្រាងច្បាប់ពាក់ព័ន្ធចំនួន ៣





សំខាន់ៗរួមមាន ៖

១-ការពិនិត្យ និងអនុម័តលើកំណត់ហេតុនៃកិច្ចប្រជុំរបស់ គ.ជ.អ.ប លើកទី ១៩ ។

២-ពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារស្តីពីផែនការអនុវត្តរយៈពេលប្រាំឆ្នាំដំណាក់កាលទី១(២០២១-២០២៥) ។

៣-ពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន ៣ទៀត រួមមាន ៖

**សេចក្តីព្រាងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ សេចក្តីព្រាងច្បាប់ ស្តីពី ជលផល សេចក្តីព្រាងច្បាប់ស្តីពីព្រៃឈើ និងការងារពាក់ព័ន្ធមួយចំនួនទៀត** ។ ជាមួយគ្នានោះក៏ និងពិនិត្យមើលឡើងវិញពីរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រង ការបែងចែកមុខងារ និងសិទ្ធិអំណាច តួនាទី ភារកិច្ច រវាងក្រសួង-

២១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







តមកពីទំព័រ ២០

## កិច្ចប្រជុំលើកទី២០ របស់ គ ជ អ ប ...

ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឱ្យការប្រគល់មុខងារនេះស្របតាមគោលនយោបាយអភិវឌ្ឍន៍ និងលើកកម្ពស់គោលនយោបាយមុខងារសាធារណៈសំដៅចូលរួមចំណែកលុបបំបាត់ភាពក្រីក្រ លើកកម្ពស់គុណភាពសិទ្ធិរបស់ប្រជាពលរដ្ឋ ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បន្តថា៖ ក្នុងការអនុវត្តគោលនយោបាយថ្នាក់ជាតិ២០១០-២០២០ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងនានា ព្រមទាំងក្រសួងមហាផ្ទៃ ផងដែរ បានផ្ទេរមុខងារសិទ្ធិអំណាច និងធនធានមួយចំនួនធំទៅថ្នាក់ក្រោមជាតិ ហើយកិច្ចការនេះត្រូវបានរៀបចំជាជំហាន និងជាដំណាក់កាល ដោយមានការពិភាក្សានិងពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធផងដែរ ។ ទន្ទឹមនេះ ក្នុងដំណើរការធ្វើវិមជ្ឈការ និងវិសហមជ្ឈការកន្លងមកនេះ ក្រសួងមហាផ្ទៃ បានផ្ទេរសិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវជាច្រើនរួចមកហើយ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជា**ការផ្ទេរសិទ្ធិអំណាច ធនធាន និងការទទួលខុសត្រូវលើការគ្រប់គ្រងការផ្តល់សេវារដ្ឋបាល ជូនប្រជាពលរដ្ឋ ការផ្ទេរបុគ្គលិកក្របខណ្ឌក្រសួងមហាផ្ទៃ ប្រមាណជាង ៧.០០០នាក់ ទៅស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ។

ឯកឧត្តម **ចាន់ សុធា** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប បានធ្វើសេចក្តីរាយការណ៍សង្ខេប ស្តីពី សេចក្តីព្រាងផែនការអនុវត្តរយៈពេលប្រាំឆ្នាំដំណាក់កាលទី១ (២០២១-២០២៥) នៃកម្មវិធីជាតិដំណាក់កាលទី២ គោរពជូន**សម្តេចក្រឡាហោម**និងអង្គប្រជុំថា៖ រាជរដ្ឋាភិបាល បានចាត់ទុកកំណែទម្រង់អភិបាលកិច្ច គឺជាកិច្ចការដ៏ចាំបាច់ និងមានសារៈសំខាន់ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបាននូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាល បាននឹងកំពុងធ្វើទំនើបកម្មយ៉ាងទូលំទូលាយ និងស៊ីជម្រៅនូវប្រព័ន្ធអភិបាលកិច្ចតាមរយៈកម្មវិធីកំណែទម្រង់នានា រួមមានកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬហៅថាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់តាមវិស័យនានា ។ ក្នុងនោះដើម្បីឱ្យការធ្វើកំណែទម្រង់ខាងលើមានប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាល បានរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាដំណាក់កាលៗ ដើម្បីផ្សារភ្ជាប់ជាមួយនឹងកម្មវិធីកំណែទម្រង់ស្នូល និងកំណែទម្រង់តាមវិស័យនានារបស់រាជរដ្ឋាភិបាល ដែលការរៀបចំនូវសេចក្តីព្រាងផែនការអនុវត្តរយៈពេលប្រាំឆ្នាំដំណាក់កាលទី១ គឺបានផ្តោតលើមូលដ្ឋានសំខាន់ៗមួយចំនួនរួមមាន៖ កម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០) ឯកសារ ស្តីពី កិច្ចការអន្តរវិស័យនានាដែល



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



បានកំណត់ក្នុងកម្មវិធីជាតិដំណាក់កាលទី២ (២០២១-២០៣០) ក្នុងនោះ រួមមាន៖ **ការលើកកម្ពស់សមភាពយេនឌ័របរិយាបន្ន និងសមធម៌សង្គម ការកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងជំងឺឆ្លងនានា កម្មវិធីកំណែទម្រង់ស្ថាប័ននានា និងគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ព្រមទាំងឈិទិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗផងដែរ** ។

ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានធ្វើសេចក្តីរាយការណ៍ ជូនអង្គប្រជុំជ្រាបថា៖ កត្តាសំខាន់ៗជាមូលដ្ឋាន ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី **តំបន់ការពារធម្មជាតិ** និងសេចក្តីព្រាងច្បាប់ ស្តីពី **ព្រៃឈើ** គឺផ្អែកលើការរីកចម្រើនរបស់ប្រទេស និងជីវភាពប្រជាជននៅទូទាំងប្រទេស ដែលទាមទារឱ្យមានការថែរក្សាការពារតំបន់ធនធានធម្មជាតិនានាគ្រប់ប្រភេទនៅក្នុងប្រទេស រួមមាន **ព្រៃឈើ ទន្លេ បឹងបួរ ភ្នំ** និងសម្បត្តិធម្មជាតិមួយចំនួនទៀត សម្រាប់តម្កល់ជាសម្បត្តិជាតិដែលមានរយៈពេលយូរអង្វែង និងអាចទាញយកនូវផលប្រយោជន៍ជូនជាតិ និងប្រជាជនត្រឡប់មកវិញ ដែលឯកឧត្តម បានចាត់ទុកថា នេះក៏ជាការត្រៀមខ្លួន ដើម្បីរៀបចំសណ្តាប់ធ្នាប់សាធារណៈរបស់ពិភពលោកឱ្យបានល្អប្រសើរផងដែរ ។

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានប្រសាសន៍បន្តថា៖ បច្ចុប្បន្នប្រជាជនមានការយល់ដឹងច្រើន និងមានស្មារតីចូលរួមក្នុងកិច្ចការការពារធនធានធម្មជាតិនេះជាមួយរាជរដ្ឋាភិបាលយ៉ាងច្រើនកុះករ ។ ទន្ទឹមនឹងនេះ ក្នុងនាមក្រសួងបរិស្ថាន ដែលជាសេនាធិការលើការងារពាក់ព័ន្ធទាំងនេះ ឯកឧត្តមយល់ឃើញថាត្រូវមានច្បាប់ថ្មីមួយ ដើម្បីមានលក្ខណៈគ្រប់គ្រាន់សម្រាប់អនុវត្តលើកិច្ចការងារនេះឱ្យស្របជាមួយការវិវត្តរបស់សង្គមនាពេលបច្ចុប្បន្ននោះ គឺច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ។ ដែលច្បាប់ស្តីពី តំបន់ការពារធម្មជាតិនេះមានគោលបំណងសម្រាប់កំណត់អំពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ប្រកបដោយនិរន្តរភាព ដើម្បីធ្វើការការពារ និងអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី បេតិកភណ្ឌវប្បធម៌ បេតិកភណ្ឌធម្មជាតិ ព្រមទាំងលើកកម្ពស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ជីវភាពសហគមន៍មូលដ្ឋាន អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងតំបន់ការពារធម្មជាតិ ។ លើសពីនេះ ច្បាប់ស្តីពីព្រៃឈើគឺមានគោលបំណងកំណត់អំពីការគ្រប់គ្រង ការអភិរក្ស ការអភិវឌ្ឍ ការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់ព្រៃឈើប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដើម្បីផលប្រយោជន៍ **សង្គម សេដ្ឋកិច្ច និងបរិស្ថាន** ។

ពាក់ព័ន្ធ និងសេចក្តីព្រាងច្បាប់ស្តីពីជលផល ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់ថា៖ ឯកឧត្តម បានជំរុញដល់ដំណើរការនៃការរៀបចំក្រុមការងារក្រសួងនៅក្នុងការធ្វើការពិនិត្យរៀបចំកែសម្រួលយ៉ាងយកចិត្តទុកដាក់ និងមានវឌ្ឍនភាពយ៉ាងល្អប្រសើរ ។

ជាមួយគ្នានេះ ឯកឧត្តម **ព្រុំ សុផា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល បានធ្វើសេចក្តីរាយការណ៍លម្អិតអំពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីជលផល ដែលច្បាប់នេះមានគោលបំណង ដើម្បីឆ្លើយតបទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍបច្ចេកវិទ្យា សេដ្ឋកិច្ចសង្គម ការធ្វើសមាហរណកម្មវិស័យជលផលកម្ពុជាទៅក្នុងតំបន់ និងអន្តរជាតិ ក្នុងការគ្រប់ គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅវិស័យជលផលរបស់រាជរដ្ឋាភិបាលជាពិសេសផ្តោតសំខាន់ទៅលើបទបញ្ញត្តិមួយចំនួន ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនេសាទសមុទ្រ។ ឯកឧត្តម បានបញ្ជាក់ថា សេចក្តីព្រាងច្បាប់ ស្តីពី ជលផល បានពិនិត្យពិភាក្សា និងកែសម្រួលជាបន្តបន្ទាប់តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់នានាជាសាធារណៈជាមួយអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធសម្រេចបានជាសេចក្តីសម្រេចចុងក្រោយ មាន១៧ជំពូក និង១២៩មាត្រា ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ពិធីប្រគល់-ទទួល ទីស្នាក់ការច្រកទ្វារអន្តរជាតិម៉ឺនជ័យ ដំណាក់កាលទី ៣ និងវាយតម្លៃបញ្ចប់សុពលភាព សំណង់ដំណាក់កាលទី ២



ឯកឧត្តម នាយឧត្តមសេនីយ៍ សេង យូអ៊ាន់ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ



កាលពីព្រឹកថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២២ កន្លងមកនេះ ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ម៉ុនណារិន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការលទ្ធកម្ម (គ.ល) បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់-ទទួលទីស្នាក់ការច្រកទ្វារអន្តរជាតិម៉ឺនជ័យ( ដំណាក់កាលទី៣ )ស្ថិតក្នុងឃុំក្របៅ ស្រុកកំ ចាយមារ ខេត្តព្រៃវែង ។

ក្នុងរបាយការណ៍របស់ ឧត្តមសេនីយ៍ទោ **គឹម ម៉េងហេង** ប្រធានអង្គភាពលទ្ធកម្មបានឱ្យដឹងថា៖ ការប្រគល់-ទទួលនាពេលនេះមានដូចជា៖ ទី១-ពិធីប្រគល់-ទទួលទីស្នាក់ការច្រកទ្វារអន្តរជាតិម៉ឺនជ័យ (ដំណាក់កាលទី៣) ទី២-ការត្រួតពិនិត្យនិងវាយតម្លៃបញ្ចប់សុពលភាពសំណង់ទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ( ដំណាក់កាលទី២) មានដូចជាចាក់ដីបំពេញបរិវេណទីតាំងសាងសង់អគារបំពេញបែបបទទទួលភ្ញៀវទេសចរណ៍ចំនួន ១ខ្នង អគារស្នាក់ នៅចំនួន ២ខ្នង ផ្ទះដាំបាយ និង





ឧត្តមសេនីយ៍ទោ គឹម ម៉េងហេង ប្រធានអង្គភាពលទ្ធកម្ម



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



ហូបបាយចំនួន ១ខ្នង ក្លោងទ្វារចម្លាក់ប្រាសាទអង្គរចំនួន ១កន្លែង តម្លើងតុបញ្ជរ(Counter)ចំនួន៥ឈុត និងបំពាក់ម៉ាស៊ីនត្រជាក់ចំនួន ៤០គ្រឿង ក្នុងអគារបំពេញបែបបទ និងអគារទទួលភ្ញៀវទេសចរណ៍ ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។



ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា៖ ដំណើរការសាងសង់ទីស្នាក់ការច្រកទ្វារអន្តរជាតិ ប៉ឹនដីយ នេះគឺអនុវត្តតាមចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ស្តីពីការប្រគល់កិច្ចសន្យាជូននាយកដ្ឋានស្ថាប

៤៣





៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 9:59 AM



# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន

## ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម ឯកអគ្គរាជទូតថ្មី នៃចក្រភពអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា





រសៀលថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ដូមីនិច វីលៀម** (**Dominic Williams**) ឯកអគ្គរាជទូតថ្មីនៃចក្រភពអង់គ្លេសប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក **ភីតធ័រ វើណុន** (**Peter Vernon**) មន្ត្រីទំនាក់ទំនង NCA (National Crime Agency) ព្រមទាំងសហការីនៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

នៅក្នុងជំនួបនោះ ជាកិច្ចចាប់ផ្តើម ឯកឧត្តម ឯកអគ្គរាជទូតអង់គ្លេសប្រ ចាំនៅកម្ពុជា បានបញ្ជាក់ពីកិច្ចសហប្រតិបត្តិការដ៏ល្អកន្លងមករវាងផ្នែកស្ថានកុងស៊ុលនៃស្ថានទូតអង់គ្លេសប្រចាំនៅកម្ពុជា និងនគរបាលជាតិកម្ពុជា ក៏ដូចជាមន្ត្រីនៃក្រសួងមហាផ្ទៃផងដែរ ។ ទន្ទឹមនេះ ឯកឧត្តម



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/pebw/





ក៏បានថ្លែងការកោតសរសើររាល់កិច្ចសហប្រតិបត្តិការទាំងអស់តែងតែរក្សាបាននូវការគោរពសិទ្ធិមនុស្ស ក្នុងនោះក៏បានបង្ហាញពីការប្តេជ្ញាចិត្តជាមួយនគរបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសជួញដូរមនុស្សឆ្លងដែន ជាពិសេសបទល្មើសរំលោភផ្លូវភេទលើកុមារ ព្រមទាំងបានបញ្ជាក់អំពីការជួយចែករំលែកទាំងបទពិសោធន៍ និងការបណ្តុះបណ្តាលជំនាញដល់នគរបាលជាតិកម្ពុជា បន្តទៀតផងដែរ ។

ជាការឆ្លើយតបវិញ ឯកឧត្តម **នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត** អគ្គស្នងការនគរបាលជាតិ បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារជាតិ NCA ជាមួយនិងនគរបាលជាតិកម្ពុជានិងថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដែលផ្តល់ដោយ NCA ពាក់ព័ន្ធ និងការបណ្តុះបណ្តាលមន្ត្រី ការផ្តល់អាហារូបករណ៍ដល់មន្ត្រីនគរបាលជាតិកម្ពុជាទៅសិក្សានៅប្រទេសអង់គ្លេស ព្រមទាំងការជំរុញកិច្ចសហប្រតិបត្តិការបានល្អប្រសើរតាមខ្លឹមសារអនុស្សរណៈនៃការយោគយល់គ្នានិងការផ្តល់ជាមធ្យោបាយសម្ភារបច្ចេកទេសពាក់ព័ន្ធនិងការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា ។ ហើយតាមរយៈនេះ ឯកឧត្តម **នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត** អគ្គស្នងការនគរបាលជាតិ សង្ឃឹមថាភាគីទាំងពីរនិងបន្តកិច្ចសហប្រតិបត្តិការឲ្យកាន់តែមានលទ្ធផលល្អបន្ថែមទៀត ។

ឯកឧត្តម ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ក៏បានថ្លែងការកោតសរសើរផងដែរចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ឯកឧត្តម **នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត** អគ្គស្នងការនគរបាលជាតិ ដែលជាប្រធានអនុគណៈកម្មការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសង្គ្រោះ ដែលបានការពារយ៉ាងល្អប្រសើរជូនគណៈប្រតិភូកំពូល ក្នុងអំឡុងពេលនៃការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលកម្ពុជាធ្វើជាប្រធាន និងបានបញ្ជាក់អំពីការរីករាយស្វាគមន៍ចំពោះការត្រៀមរៀបចំ MOUថ្មី ដែលគ្រោងនឹងចុះហត្ថលេខា ក្នុងឆ្នាំ២០២៣ ខាងមុខ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ក្រុមការងារអន្តរក្រសួង បន្តពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពី គោរមងារ ឧកញ៉ា ពីជំពូក ៤ ដល់ជំពូក ៧



នៅព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមកនេះ ក្រសួងមហាផ្ទៃ បានបើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីបន្តពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីគោរមងារឧកញ៉ា ក្រោមអធិបតីភាព ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារអន្តរក្រសួង ដោយមានការអញ្ជើញចូលរួមពីសំណាក់ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធដែលជាអនុប្រធានក្រុមការងារ និងសមាជិកក្រុមការងារអន្តរក្រសួង ដើម្បីសិក្សារៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រង ឧកញ៉ា ការផ្តល់គោរមងារឧកញ៉ា និងការដកហូតគោរមងារឧកញ៉ា ។

នាឱកាសនោះ ឯកឧត្តម រដ្ឋលេខាធិការនិងជាប្រធានក្រុមការងារអន្តរក្រសួង បានមានប្រសាសន៍បញ្ជាក់ថា៖កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពី គោរមងារឧកញ៉ា នេះបានធ្វើឡើងចំនួន៤លើករួចមកហើយ ដោយអង្គប្រជុំបានពិនិត្យ និងពិភាក្សាសម្រេចបានចំនួន ៣ជំពូក រួមមានជំពូកទី១ ទី២







៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




និងទី៣នៃសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពី គោរពមរណទុកញ៉ា ហើយកិច្ចប្រជុំថ្ងៃនេះនឹងបន្តពិនិត្យពិភាក្សាលើជំពូកទី ៤ ដល់ជំពូកទី៧ ជាបន្តទៀត ។

សូមជម្រាបជូនថា៖ ព្រះរាជក្រឹត្យស្តីពី គោរមងារទុកញ៉ា មានចំនួន ១០ជំពូក និង ២៦មាត្រា ហើយព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលជាប្រជាពលរដ្ឋខ្មែរ ដែលទទួលបានគោរមងារទុកញ៉ា នៅព្រះរាជាណាចក្រកម្ពុជា ។

សូមរំលឹកជូនដែរថា៖ ក្រុមការងារអន្តរក្រសួង ត្រូវបានរាជរដ្ឋាភិបាលបង្កើតឡើងនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ដើម្បីសិក្សាស្រាវជ្រាវ ផ្តួចផ្តើមក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងទុកញ៉ា ការផ្តល់គោរមងារទុកញ៉ា ការដកហូតគោរមងារទុកញ៉ា និងសិក្សាស្រាវជ្រាវច្បាប់លិខិតបទដ្ឋានគតិយុត្តនានា ដើម្បីជាធាតុចូលសម្រាប់រៀបចំការគ្រប់គ្រងទុកញ៉ា ការផ្តល់គោរមងារទុកញ៉ា និងការដកហូតគោរមងារទុកញ៉ា ដែលមានសមាសភាពចំនួន១២រូប ក្នុងនោះមានឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន និងអនុប្រធានចំនួន ១រូប ព្រមទាំងសមាជិកចំនួន ១០រូបដែលជាតំណាងក្រសួង - ស្ថាប័នពាក់ព័ន្ធ ។





ក្រុមការងារនេះមានភារកិច្ចសិក្សាអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ទុកញ៉ាក្នុងការចូលរួមកិច្ចការសង្គម ធ្វើការពិគ្រោះយោបល់ជាមួយបណ្តាក្រសួង-ស្ថាប័នអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មានបម្រើឱ្យការរៀបចំបែបបទ និងនីតិវិធីនៃការគ្រប់គ្រងទុកញ៉ា ការស្នើសុំផ្តល់គោរមងារទុកញ៉ា អ្នកទុកញ៉ា និងការដកហូតគោរមងារទុកញ៉ា៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន
## ក្រសួងនគរបាលអមស្ថានទូតវៀតណាមប្រចាំកម្ពុជា





នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតឲ្យលោក **ឡេ វ៉ាន ភួង** (LE VAN PHUONG) ប្រធានស្ថានតំណាងក្រសួងនគរបាល អមស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការីចូលជួបសម្តែងការគួរសម និងឧទ្ទេសនាមលោក **ង្វៀន វ៉ាន គួង** (NGUYEN VAN CUONG) អនុប្រធានទទួលកិច្ចការតម្រួត ព្រមទាំងរាយការណ៍អំពីលទ្ធផលកិច្ចសហប្រតិបត្តិការកន្លងមក នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ។

ក្នុងជំនួបនោះ លោកប្រធានស្ថានតំណាងក្រសួងនគរបាល អមស្ថានទូតវៀតណាមប្រចាំកម្ពុជា និងលោកអនុប្រធានទទួលកិច្ចការតម្រួត បានរាយការណ៍ជូនឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត

22/5/23, 9:59 AM



# អនុញ្ញាតិឲ្យលោក LE VAN PHUONG ប្រធានតំណាង ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ



អគ្គស្នងការនគរបាលជាតិ អំពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងនគរបាលជាតិកម្ពុជា និងនគរបាលវៀតណាមដែលសម្រេចបានក្នុងឆ្នាំ២០២២ និងទិសដៅអនុវត្តន៍បន្តនាពេលខាងមុខ និងបានស្នើសុំអនុសាសន៍ចង្អុលដឹកនាំបំពេញបន្ថែមពី ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ លើកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនគ្រប់ប្រភេទ ពិសេសដើម្បីបង្កើនការធានាសន្តិសុខ និងសណ្តាប់ធ្នាប់ជារួមនៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ។

ជាការឆ្លើយតប ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានថ្លែងនូវការកោតសរសើរ និងគាំទ្រដល់លទ្ធផលនៃកិច្ចសហប្រតិបត្តិការកន្លងមកដែលភាគីទាំងពីរសម្រេចបានក្នុងឆ្នាំ២០២២នេះ ។ ជាអនុសាសន៍ដឹកនាំបន្ថែមលើលទ្ធផលល្អដែលមានស្រាប់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត អគ្គស្នងការនគរបាលជាតិ បានចង្អុលដឹកនាំ ឲ្យនាយកដ្ឋាន-អង្គភាពជំនាញនៃភាគីទាំងពីរ **បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរព័ត៌មានទាន់ពេលវេលាកន្លែងរវាង...**

**បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរព័ត៌មានទាន់ហេតុការណ៍និងបទពិសោធន៍ ព្រមទាំងពង្រឹងការសម្របសម្រួលរួមសហការដោះស្រាយប្រយុទ្ធប្រឆាំងបទល្មើសឲ្យបានទាន់ពេលវេលា ចំគោលដៅ និងមានប្រសិទ្ធភាពនិយាយជារួមសហការដោះស្រាយកុំឲ្យបទល្មើសមានការរីករាលដាល ។**

ក្នុងជំនួបនេះ ភាគីនគរបាលទាំងពីរកម្ពុជា-វៀតណាម ក៏បានប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការឲ្យបានល្អប្រសើរបន្ថែមទៀតរវាងស្ថាប័នអនុវត្តច្បាប់នៃប្រទេសទាំងពីរ ក្នុងការបង្ការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/pebw/

# គណៈប្រតិភូ អគ្គនាយកដ្ឋានភស្តុភារ និង ទស្សនកិច្ចដកបទពិសោធន៍ការងារនៅ







កាលពីថ្ងៃទី២២ ដល់ថ្ងៃ២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូរ៉េន** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុចំនួន០៨រូប ធ្វើទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ការងារ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

ក្នុងឱកាសស្នាក់អាស្រ័យនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ គណៈប្រតិភូបានជួបប្រជុំពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ ជាមួយលោកឧត្តមសេនីយ៍ ត្រី**ថខស៊ុត យ៉ាអឺឡាវលី** អគ្គនាយករង្គទីនៃអគ្គនាយកដ្ឋានភស្តុភារក្រសួងសន្តិសុខសាធារណៈឡាវ ព្រមទាំងថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទផ្សេងទៀត ដែលជំនួបប្រជុំនេះផ្តោតសំខាន់លើការអនុវត្តកំណត់ហេតុស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីប្រចាំឆ្នាំ២០២២ ផ្លាស់ប្តូរបទពិសោធន៍ការងារដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទាំងពីរបាននឹងកំពុងអនុវត្តជាក់ស្តែង និងជម្រាបជូនគ្នាទៅវិញទៅមកអំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ព្រមទាំងកិច្ចការចាំបាច់មួយចំនួនផ្សេងទៀត ដែលអង្គភាពក្រោមឱវាទចំណុះអគ្គនាយកដ្ឋាននៃក្រសួងទាំងពីរបាន និងកំពុងបំពេញភារកិច្ចក្នុងបុព្វហេតុ រក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋរបស់ខ្លួន ។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 9:59 AM

# ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ កម្ពុជា អញ្ជើញ
# សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ



អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃកម្ពុជា បាននាំនាំនូវប្រសាសន៍ផ្ដាំផ្ញើសាកសួរសុខទុក្ខប្រកបដោយមនោសញ្ចេតនាស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីសំណាក់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្ញើជូនចំពោះ ឯកឧត្តម អនុរដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈឡាវ ព្រមទាំងរាយការណ៍ជូនអំពីលទ្ធផលប្រកបដោយផ្លែផ្កានៃជំនួបពិភាក្សាផ្លាស់ប្ដូរបទពិសោធន៍ការងាររវាងអគ្គនាយកដ្ឋានភស្តុភារទាំងពីរ (កម្ពុជា-ឡាវ) ។

មុនពេលបញ្ចប់ដំណើរទស្សនកិច្ចរបស់ខ្លួន គណៈប្រតិភូក៏បានចូលជួបសម្ដែងការគួរសម ជាមួយឯកឧត្តម **ខាំគីខ តុយឡាម:នីវង្ស** សមាជិកមជ្ឈឹមបក្សនិងជាអនុរដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលនៅក្នុងជំនួបសំដែងការគួរសមនោះ ឯកឧត្តម នាយឧត្តមសេនីយ៍

ជាការឆ្លើយតបវិញ ឯកឧត្តម អនុរដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈឡាវ បានធ្វើការវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការ រវាងក្រសួងមហាផ្ទៃ







នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និយាយរួម និងនិយាយដោយឡែករវាងអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុទាំងពីរនៅក្នុងឆ្នាំ២០២២ ដែលទទួលបានលទ្ធផលល្អប្រសើរ ជាពិសេស ឯកឧត្តម អនុរដ្ឋមន្ត្រីបានមានប្រសាសន៍ កត់សំគាល់ថា ៖

៣៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/pebw/







តមកពីទំព័រ ៣២

**គណៈប្រតិភូ អគ្គនាយកដ្ឋានភស្តុភារ និង ...**

អគ្គនាយកដ្ឋានទាំងពីរ ( ***អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុកម្ពុជា និងអគ្គនាយកដ្ឋានភស្តុភារឡាវ*** ) មានរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចប្រហាក់ប្រហែលគ្នាដែលផ្តល់ភាពងាយស្រួលក្នុងការដកពិសោធន៍ការងារពីគ្នាទៅវិញទៅមក ប៉ុន្តែអគ្គនាយកដ្ឋានភស្តុភារនៃក្រសួងសន្តិសុខសាធារណៈឡាវ មានតួនាទី និងភារកិច្ចផ្គត់ផ្គង់ជូនតែកងកម្លាំងនគរបាលតែប៉ុណ្ណោះ ខុសពីអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃកម្ពុជា ដែលមានតួនាទី និងភារកិច្ចផ្គត់ផ្គង់ទាំងកងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ។

ទន្ទឹមនេះ ឯកឧត្តម អនុរដ្ឋមន្ត្រីក៏បានស្នើអគ្គនាយកដ្ឋានទាំងពីរបន្តការអនុវត្តកិច្ចសហប្រតិបត្តិការប្រចាំឆ្នាំ ដែលមានស្រាប់ និងបង្កើនការផ្លាស់ប្តូរបទពិសោធន៍ជាមួយគ្នាឱ្យកាន់តែស៊ីជម្រៅថែមទៀត ។



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ដែលក្នុងនោះត្រូវខិតខំរួមគ្នាថែរក្សាសន្តិភាព និងទំនាក់ទំនងមិត្តភាពជាបងប្អូនភូមិផងរបងជាមួយគ្នារួមសុខរួមទុក្ខជាមួយគ្នា និងជួយយកអាសារគ្នាទៅវិញទៅមក ។

គួរបញ្ជាក់ដែរថា៖ ក្រៅពីជំនួបពិភាក្សាការងារ គណៈប្រតិភូអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ក៏បានធ្វើទស្សនកិច្ចសិក្សាស្វែងយល់អំពីខ្សែចង្វាក់ផលិតកម្មរោងចក្រកាត់ដេរសំលៀកបំពាក់ **គៀន សុន្ថិស៊ុគ** ដែលជាការវិនិយោគភាគហ៊ុនរួមគ្នា រវាងអគ្គនាយកដ្ឋានភស្តុភារ និងអ្នកវិនិយោគក្នុងស្រុក សម្រាប់ផ្គត់ផ្គង់ឯកសណ្ឋានជូនកងកម្លាំងនគរបាលទូទាំងប្រទេសឡាវ ដែលរោងចក្រកាត់ដេរនេះមានទីតាំងនៅក្នុងរាជធានីវៀងចន្ទ ព្រមទាំងទស្សនាតំបន់រមណីយដ្ឋានសំខាន់ៗមួយចំនួនទៀត ៕



**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# កិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារ ឆ្នាំ ២០២១ និង ឆ្នាំ ២០២២ របស់ក្រុមការងារ SOMTC–កម្ពុជា

## ព្រមទាំងទិសដៅការងារបន្ត



នាព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ តត្តិ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា Senior Officials Meeting on Transnational Crime (SOMTC) បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការងារឆ្នាំ២០២១ និងឆ្នាំ២០២២ ព្រមទាំងទិសដៅការងារបន្តរបស់ក្រុមការងារ SOMTC-កម្ពុជា ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកានៃក្រុមការងារ SOMTC ព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត ។

លោកជំទាវ **ទីរត្ន ទិដ្ឋតា** អគ្គលេខាធិការរង និងជាអនុប្រធានប្រចាំការក្រុមលេខាធិការនៃក្រុមការងារ SOMTC-កម្ពុជា បានធ្វើសេចក្តីរាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពការងារឆ្នាំ២០២១ និងឆ្នាំ២០២២ ព្រមទាំងទិសដៅការងារបន្តរបស់ក្រុមការងារ SOMTC-កម្ពុជា ដោយលោកជំទាវ បានឱ្យដឹងថា៖ ក្នុងឆ្នាំ២០២១កន្លងទៅ ក្រុមការងារ SOMTC-កម្ពុជាបាន ចូលរួមកិច្ចប្រជុំ SOMTC លើកទី២១ និងកិច្ចប្រជុំ AMMTC លើកទី១៥ ចំនួន២៧កិច្ចប្រជុំ និងបានចូលរួម







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ ចំនួន ៣៨លើក ។

ជាមួយគ្នានេះដែរ ក្រុមការងារ SOMTCដែលជាតំណាងនៃក្រុមការងារទទួលផែននីមួយៗ បានធ្វើបទបង្ហាញអំពីរបាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពការងារឆ្នាំ២០២១ និងឆ្នាំ២០២២ ព្រមទាំងទិសដៅការងារបន្តដែលមានការលើកឡើងនូវសំណើរ សំណូមពរ និងបញ្ហាប្រឈមដែលផែនទទួលបន្ទុកនីមួយៗជួបប្រទះ ព្រមទាំងផែនការដែលត្រូវត្រៀមលក្ខណៈសម្រាប់ជំរុញការងារនៅឆ្នាំបន្តបន្ទាប់ទៀតជូនអង្គប្រជុំផងដែរ ។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សមាជិក សមាជិកានៃក្រុមការងារ SOMTC នាពេលកន្លងមក ក៏ដូចជាការចូលរួមកិច្ចប្រជុំនានា តាមផែនការនៃការទទួលខុសត្រូវនៃយន្តការរបស់អាស៊ាន ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែនដែលកន្លងមកកម្ពុជាបានធ្វើជាម្ចាស់ផ្ទះប្រកបដោយជោគជ័យជាទីមោទនៈ។ ទន្ទឹមនេះ បើទោះបីស្ថិតនៅក្នុងស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩ក្តី តែសមាជិក សមាជិកានៃក្រុមការងារ SOMTC បានចំណាយពេលវេលាក្នុងការចូលរួមបណ្តាកិច្ចប្រជុំ ក៏ដូចជាការបណ្តុះបណ្តាលនានា ពាក់ព័ន្ធទៅនឹងបទល្មើសឧក្រិដ្ឋកម្មឆ្លងដែនយ៉ាងសកម្មក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២កន្លងមក ។ ព្រមជាមួយនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ ក៏បានថ្លែងអំណរគុណផងដែរចំពោះកិច្ចសហប្រតិបត្តិការល្អប្រសើររវាងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានបំពេញការងាររួមគ្នាក្លាយទៅជាយន្តការមួយដែលដំណើរការបានទាំងថ្នាក់ជាតិ-អន្តរជាតិ និងកម្រិតតំបន់ជាពិសេសការចូលរួមជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន ព្រមទាំងសមត្ថភាពក្នុងការធ្វើជាម្ចាស់ផ្ទះ ក៏ដូចជានាំមកនូវជោគជ័យថ្មីៗថែមទៀតក្នុងនាមជាលេខាធិការ ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ជាពិសេសជាលេខាធិការរបស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលជាប្រធាននៃ AMMTC ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# សិក្ខាសាលាស្តីពី «ការផ្សព្វផ្សាយកម្មវិធី

សិក្ខាសាលាស្តីពី « **ការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** » បានរៀបចំឡើងនៅសណ្ឋាគារ ស្ទឹងសង្កែ ខេត្តបាត់ដំបង រយៈពេលពីរថ្ងៃ( ៨-៩ ខែធ្នូ ឆ្នាំ២០២២ ) បានបញ្ចប់ដោយជោគជ័យក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **សេង យូអ៊ាន់** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ និងជាប្រធានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងមហាផ្ទៃ ។

ក្នុងរបាយការណ៍បូកសរុបលទ្ធផលអំពីដំណើរការអង្គសិក្ខាសាលាដែលអានដោយ លោកឧត្តមមន្ត្រីថ្នាក់លេខ៥ **ហួត ដាវីត** ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្នែករដ្ឋបាលទូទៅ បានបញ្ជាក់ថា៖ អង្គសិក្ខាសាលាក្នុងរយៈពេល២ថ្ងៃនេះបានប្រព្រឹត្តទៅដោយរលូន



លោកឧត្តមមន្ត្រីថ្នាក់លេខ៥ **ហួត ដាវីត** ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្នែករដ្ឋបាលទូទៅ





៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# កែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ»





តាមការគ្រោងទុកដោយសិក្ខាកាមមានការចូលរួមក្នុងវេទិកាសំណួរ-ចម្លើយ យ៉ាងផុលផុសរវាងអ្នកធ្វើបទបង្ហាញដែលមានបទពិសោធន៍ និងសិក្ខាកាមដែលជាអ្នកអនុវត្តផ្ទាល់ ដោយយើងបានសិក្សាស្វែងយល់ពីសុខភាពប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលលទ្ធផលនេះបានតម្រង់ទិសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ទន្ទឹមនេះ ទោះបីកម្មវិធីកែទម្រង់មានភាពស្មុគស្មាញ និងតម្រូវឱ្យយើងមានភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ពីគ្រប់កម្រិតនៃរចនាសម្ព័ន្ធគ្រប់គ្រង ប៉ុន្តែយើងបានប្ដេជ្ញាចិត្តព្រមទាំងសន្យា នឹងយកពុទ្ធិដែលទទួលបាននៅថ្ងៃនេះ រួមទាំងបទពិសោធន៍នៃការអនុវត្តជាក់ស្ដែង ដើម្បីរួមសហការដើរទៅមុខរួមគ្នា ក្នុងគោលដៅចូលរួម

☞ ៤៨



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ឧត្តមសេនីយ៍ឯក ស ថេត
# ដាក់ចេញនូវផែនការឲ្យមន្ត្រីជំនាញ**អត្តសញ្ញាណកម្ម**
# **ចុះធ្វើអត្តសញ្ញាណប័ណ្ណ**ជូនប្រជាពលរដ្ឋដល់ខ្នងផ្ទះ








ឧត្តមសេនីយ៍ឯក **ស ថេត** អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានបញ្ជាក់នៅក្នុងកិច្ចប្រជុំ នាព្រឹកថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២២ស្តីពី ការត្រួតពិនិត្យសកម្មភាពការផ្តល់សេវាអត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ ដោយបានដាក់ចេញនូវផែនការយ៉ាងម៉ឺងម៉ាត់ឱ្យមន្ត្រីជំនាញអត្តសញ្ញាណកម្មអនុវត្តទាំងនៅការិយាល័យជំនាញ អធិការដ្ឋាននគរបាលខណ្ឌទាំង១៤ និងប៉ុស្តិ៍នគរបាលរដ្ឋបាលទាំង១០៥ត្រូវចុះធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋដែលគ្រប់អាយុ១៥ឆ្នាំឡើងទៅ និងអត្តសញ្ញាណប័ណ្ណផុតសុពលភាពទៅដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដើម្បីដោះស្រាយបញ្ហាកកស្ទះអត្តសញ្ញាណប័ណ្ណ និងជាពិសេស គឺដើម្បីពន្លឿនធ្វើអត្តសញ្ញាណប័ណ្ណឱ្យទាន់ពេលវេលាសម្រាប់ឱ្យប្រជាពលរដ្ឋប្រើប្រាស់ទៅចូលរួមបោះឆ្នោតសកលជ្រើសរើសសមាជិករដ្ឋសភានីតិកាលទី៧ នៅពេលខាងមុខនេះ ។

ឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ បានបញ្ជាក់ទៀតថា៖ កិច្ចការនេះបើចង់ដោះស្រាយបញ្ហាកកស្ទះអត្តសញ្ញាណប័ណ្ណឱ្យទាន់ពេលវេលាមុនថ្ងៃបោះឆ្នោតសកល គឺត្រូវជំរុញមន្ត្រីជំនាញឱ្យប្រឹងប្រែងបំពេញភារកិច្ចយ៉ាងហោចណាស់ត្រូវធ្វើអត្តសញ្ញាណប័ណ្ណជាពិសេស អត្តសញ្ញាណប័ណ្ណអស់សុពលភាពជូនប្រជាពលរដ្ឋ០១ថ្ងៃ៣៥០នាក់ (**បើតាមផែនការ គឺ១ថ្ងៃ៥៥០នាក់**)



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 9:59 AM







ទើបសម្រេចបានតាមផែនការរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ ។ កិច្ចការងារនេះផងដែរត្រូវមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីផ្សព្វផ្សាយ ជូនប្រជាពលរដ្ឋឱ្យបានដឹងជាមុនហើយត្រៀមឯកសារពាក់ព័ន្ធ ដើម្បីមន្ត្រីជំនាញចុះទៅធ្វើអត្តសញ្ញាណប័ណ្ណជូនពួកគាត់តែម្តង ។

ឧត្តមសេនីយ៍ឯក អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ ក៏បានបញ្ជាក់ទៀតថា៖ ការផ្តល់សេវាអត្តសញ្ញាណកម្មជូនប្រជាពលរដ្ឋនេះ គឺមានសារៈសំខាន់ណាស់ សម្រាប់ពួកគាត់យកទៅប្រើប្រាស់កិច្ចការងារចាំបាច់ផ្សេងៗដូច្នេះការងារផ្តល់សេវាអត្តសញ្ញាណកម្មនេះជាការងារអាទិភាព មិនត្រូវធ្វើឱ្យមានភាពយឺតយ៉ាវ បង្កឱ្យប៉ះពាល់ផលប្រយោជន៍ប្រជាពលរដ្ឋនោះទេ ដូច្នេះប្រធានអង្គភាពនីមួយៗត្រូវមានការទទួលខុសត្រូវខ្ពស់លើការងារជំនាញរបស់ខ្លួន ជាពិសេសត្រូវចុះតាមដានត្រួតពិនិត្យសកម្មភាពមន្ត្រីជំនាញរៀងរាល់ថ្ងៃដើម្បីរាយការណ៍ជូនមកថ្នាក់លើអំពីលទ្ធផល បញ្ហាប្រឈម ដើម្បីពិនិត្យសម្រេចដោះស្រាយ និងអនុវត្តវិធានការណ៍បន្ត ។

**គួរបញ្ជាក់ផងដែរថា៖** បើយោងតាមផែនការងារអត្តសញ្ញាណកម្មនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ឱ្យដឹងថា មានអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋដែលផុតសុពលភាពប្រើប្រាស់ឆ្នាំ២០២២ និងឆ្នាំ២០២៣ សរុប៦៤,៦៣៣នាក់ ក្នុងនោះគិតត្រឹមថ្ងៃទី០១ ខែសីហា ឆ្នាំ ២០២២ រហូតដល់បច្ចុប្បន្នផ្តល់បានចំនួន៧,៨៤១នាក់ បញ្ហាប្រឈមដោយសារនៅតាមបណ្តាខណ្ឌប៉ុស្តិ៍នគរបាលរដ្ឋបាលមួយចំនួនបានផ្តល់អត្តសញ្ញាណប័ណ្ណ ជូនប្រជាពលរដ្ឋមានការយឺតយ៉ាវ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/pebw/



តមកពីទំព័រ ០៦

## សម្តេចក្រឡាហោម ទទួលជួបពិភាក្សា......

**សម្តេចក្រឡាហោម** ក៏បានជម្រាបជូន ឯកឧត្តម ឯកអគ្គរដ្ឋទូតបន្ថែមទៀតថា ស្របពេលគ្នានៃការដំណើរការនៃយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សរាជរដ្ឋាភិបាលកម្ពុជា ក៏បានអនុវត្តនូវកិច្ចការសំខាន់ៗមួយចំនួនទៀតដែលរួមមាន ការប្រយុទ្ធប្រឆាំងល្បែងស៊ីសងខុសច្បាប់ ទាំងអនឡាញ និងមិនអនឡាញ ការធ្វើអាជីវកម្មហត្ថពលកម្មបរទេសនិងការងារប្រយុទ្ធប្រឆាំងការសម្អាតប្រាក់ដែលបញ្ហានេះអាស្រ័យមានសមត្ថកិច្ច កម្ពុជា បាននិងកំពុងតែបន្តអនុវត្តដើម្បីសង្គ្រោះអ្នករងគ្រោះ ទន្ទឹមគ្នានឹងផ្តន្ទាទោសជនល្មើស និងអ្នកពាក់ព័ន្ធ ហើយបន្តពង្រីកការស្រាវជ្រាវបទល្មើសទាំងនេះ ដើម្បីរកឱ្យឃើញក្នុងករណីមានការពាក់ព័ន្ធទៅនឹងបទល្មើសសម្អាតប្រាក់ ។

**សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍បញ្ជាក់ជូនឯកឧត្តម ឯកអគ្គរដ្ឋទូតផងដែរថា៖ បញ្ហាបទល្មើសជួញដូរមនុស្សនេះ គឺមិនអាចប្រទេសណាមួយអនុវត្តតែម្នាក់ឯងនោះឡើយ គឺទាមទារឱ្យមានកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក ជាពិសេសគឺរវាងកម្លាំងអនុវត្តច្បាប់ ។ ហើយកន្លងមកក៏មានការផ្សព្វផ្សាយដាក់បន្ទុកមកលើ ព្រះរាជាណាចក្រកម្ពុជា អំពីបញ្ហានេះ ក៏ប៉ុន្តែដាក់ស្តែងកិច្ចការងារនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ទាំងនៅប្រទេសគោលដៅរួមទាំងកម្ពុជា និងទាំងនៅប្រទេសដែលមានពលរដ្ឋរបស់ខ្លួនជាជនរងគ្រោះថែមទៀត។

